**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៧ សរណន

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០២

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំបុណ្យជាតិ " ទិវាកុមារអន្តរជាតិ ១ មិថុនា ២០០២ "

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ។ នៅឆ្នាំ ២០០១ ប្រទេសកម្ពុជា បានរួមចំណែកក្នុងចលនាពិភពលោកដើម្បីកុមារ ដោយបានធ្វើយុទ្ធនាការទូទាំងប្រទេស " **ផ្តល់ការគាំទ្រចំពោះកុមារ** " ដែលទទួលបានលទ្ធផលគួរជាទីពេញចិត្ត ។ លទ្ធផលទាំងនេះ ត្រូវបានរាយការណ៍ក្នុងសម័យប្រជុំពិសេស ស្តីពីកុមារនៃអង្គការសហប្រជាជាតិ ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ៨ ដល់ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០២ នៅទីក្រុង New York ។ ដើម្បីអបអរសាទរសម័យប្រជុំខាងលើ និង ក្នុងគោលបំណងពង្រឹងពង្រីកសកម្មភាពគាំទ្រដល់កុមារកម្ពុជា ដែលជាអ្នកបន្តវេនសំរាប់អនាគតនៃប្រទេសជាតិ អោយទទួលបាននូវសិទ្ធិកាន់តែល្អប្រសើរឡើងថែមទៀត ក្នុងឱកាសទិវាកុមារអន្តរជាតិ ១ មិថុនា ២០០២ ខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំដូចតទៅ :

១ - ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិ សម្បទា ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងពត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំ**ពិធីមហាយាត្រា មិទ្ទិញ** និង កម្មវិធីកំសាន្តផ្សេងៗសំរាប់កុមារនៅវត្តភ្នំ នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០២ អោយបានឱឡារិក អធិកអធម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ។

២ - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយថវិកាសំរាប់ពិធីនេះ អោយបានទាន់ពេលវេលា ដើម្បីធានាការចាត់តាំងសមស្រប តាមគោលបំណង និង សំណូមពរ ។

រាជរដ្ឋាភិបាល សូមអំពាវនាវដល់អង្គការជាតិ អន្តរជាតិ ផ្នែកឯកជន និង ប្រជាពលរដ្ឋ សូមជួយឧបត្ថម្ភគាំទ្រ ដល់កម្មវិធីនេះ អោយបានផុលផុស អធិកអធម ។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំចាត់តាំងអនុវត្ត ប្រកបដោយស្មារតីទទួលខុសត្រូវ និង មានប្រសិទ្ធភាពខ្ពស់ ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>ចម្លងជូន</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន " ដើម្បីសហការអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ